ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

បណ្តឹងឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៖ ៣៥

ចុះថ្ងៃទី២៤ - ៦ - ៩៩

សាលដីកា

លេខ ៖ ៤០

ចុះថ្ងៃទី០៨ ១២ ១៩៩៩

# តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ ៖

១ - ឯកឧត្តម ឌិត មុន្ទីរ ប្រធាន

២ - លោក ឈឹម ស៊ីផុស ចៅក្រមរបាយការណ៍

៣ - លោក សោម សិរីវឌ្ឍ ចៅក្រម

៤ - លោក ប្រាក់ គឹមសាន ចៅក្រម

៥ - លោក ឃាង់ ស៊ុនឡឹង ចៅក្រម

លោក ទ័ាន បូរ៉ាត ក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក ជួន ទេព្វង ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ៣៣ ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ ១៩៩៩របស់ឈ្មោះ ជួប សំណាង "ដើមបណ្តឹងរដ្ឋប្បវេណី" ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៨៣ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៥ ចុះថ្ងៃទី ២៤ - ០៦ - ១៩៩៩ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ វដ្ត ផុន "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៣ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកងមាស ឃុំព្នៅ ស្រុកលន្ទុក ខេត្ត កំពង់ធំ របររកស៊ី លក់ឈើ មានទីលំនៅបច្ចុប្បន្នភូមិតាក្តុល ឃុំតាក្តុល ស្រុកតាខ្មៅ ខេត្ត កណ្តាល ឪពុកឈ្មោះវដ្ត គិន "រ" ម្តាយឈ្មោះ ឈឹម ហួន "រ" ប្រពន្ធឈ្មោះ ច្បាំង សោភណ្ឌ័ មានកូន០១ នាក់។ ក្នុងឃុំ ។

- ត្រូវចោទពីបទ៖ ឆបោកប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី២៤ ០២ ៩៧

- មេធាវីការពារ អ្នកស្រី ឈឹម ស៊ីម៉ែន

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះជួប សំណាង "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ ៥១ ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ២៦បេ ក្រុម ២៦ ផ្លូវលេខ ៣៩៦ សង្កាត់ផ្សារដើមគរ ខណ្ឌ ទួលគោក ក្រុងភ្នំពេញ ។

- មេធាវីការពារលោក ខេង វីរ សុផល

- តាមពាក្យបណ្ដឹងចុះថ្ងៃទី១៥ - ១០ - ៩៧ របស់ឈ្មោះជួប សំណាង ថា ខ្លួនសុំប្ដឹងពីឈ្មោះរដ្ឋ ផុន ពីបទ ឆបោកប្រាក់ខ្លួនចំនួន ១២.៣០០ ដុល្លា កាលពីថ្ងៃទី២៤ ២ - ៩៧ ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញថា: ចោទប្រកាន់លើឈ្មោះរដ្ឋ ផុន ពីបទ: ឆបោកប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ តាមមាត្រា ៤៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១០១ "ឃ" ចុះថ្ងៃទី ០៣ - ០២ - ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារសំរេចដូចតទៅ :

១ - ផ្ដន្ទាទោសជនជាប់ចោទឈ្មោះរដ្ឋ ផុន ភេទប្រុស អាយុ ៤៣ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ពីបទ:ឆបោកប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី២៤ - ២ - ៩៧ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន៣ខែ ព្យួរក្នុងរយៈពេលសាកល្បងចំនួន៥ឆ្នាំ តាមមាត្រា ៤៥ និង ៧០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - បង្គាប់អោយឈ្មោះរដ្ឋ ផុន សងប្រាក់ចំនួន ៦៤០៧ ដុល្លានិងជម្ងឺចិត្តចំនួន៥០០ ដុល្លា ទៅអោយឈ្មោះជួប សំណាង វិញ បើឈ្មោះនេះពុំព្រមសង ត្រូវចាប់ដាក់គុកបំលំ ដល់រូបកាយតាមច្បាប់នីតិវិធីទារធនទណ្ឌ ។

៣ - សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល ២ ខែ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៦ "ង" ចុះថ្ងៃទី៣ - ០២ - ១៩៩៩ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ប្ដឹងតវ៉ាពីសាលក្រមលេខ១០១ "ឃ" ចុះថ្ងៃទី០៣ -០២ - ១៩៩៩ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: លុយដែលរដ្ឋផុន យកពីឈ្មោះជួប សំណាង គឺមានកិច្ចសន្យាព្រមព្រៀងគ្នា ដូច្នេះតាមកិច្ចសន្យានេះ តុលាការព្រហ្មទណ្ឌគ្មានសមត្ថកិច្ចទេ គឺជាសមត្ថកិច្ចតុលាការរដ្ឋប្បវេណី បើពិនិត្យពីបទល្មើសឆបោក និងបទល្មើសរំលោភសេចក្ដីទុកចិត្តក៏អត់មាន ដូចនេះសុំឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងពីរឿងរដ្ឋប្បវេណីវិញ ។ ខ្ញុំសុំមិនចោទប្រកាន់ទេ គឺសុំអោយជនជាប់ចោទរួចផុតពីបទចោទ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៨៣ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១ - ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ៣ - ២ - ៩៩ របស់លោកព្រះរាជអាជ្ញារង អមតុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ០១ "ង" ចុះថ្ងៃទី៣ - ២ - ៩៩ របស់តុលាការក្រុងភ្នំពេញចោលជាអាសារបង់ ។

៣ - អោយឈ្មោះរដ្ឋ ផុន ភេទប្រុស អាយុ៤៣ ឆ្នាំ ទីលំនៅភូមិតាក្ដុល ឃុំ

ព្រែកហូរ ស្រុកតាខ្មៅ ខេត្ត កណ្ដាល រួចខ្លួនពីបទ: ចោទប្រកាន់ពីបទឆបោក ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី២៤ - ០២ - ១៩៩៧ តាមមាត្រា ៤៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤ - បង្គាប់ឱ្យដោះលែងឈ្មោះរដ្ឋ ផុន ភ្លាម ប្រសិនបើឈ្មោះនេះ ពុំមានជាប់ពីបទផ្សេងទៀតទេ ។

៥ - ទុកសិទ្ធិឱ្យឈ្មោះជួប សំណាង ប្ដឹងទាមទារសំណងនិងការខាតបង់ផ្សេងៗ ទៅតុលាការរដ្ឋប្បវេណី ។

៦ - សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទនិងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ ៣៣ ចុះថ្ងៃទី៩ - ០៤ - ១៩៩៩ របស់ឈ្មោះជួប សំណាង ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៨៣ ចុះថ្ងៃទី ៩ - ០៤ - ១៩៩៩ របស់សាលា ឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ២៥ - ០៧ - ១៩៩៩ របស់ឈ្មោះ ជួប សំណាង

- បានឃើញសារណាឆ្លើយតបចុះថ្ងៃទី ០៦ - ០៨ - ១៩៩៩ របស់ឈ្មោះរដ្ឋ ផុន

- បានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ក្នុងរឿងនេះពុំមានធាតុផ្សំបទល្មើសទេ ជនល្មើសពុំមានកលឆបោកទេ រឿងនេះមានពាក់ព័ន្ធច្បាប់កិច្ចសន្យាលក់ទិញ ដែលជារឿងរដ្ឋប្បវេណី ហេតុនេះមហាអយ្យការសូមតុលាការតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ។

- បានស្ដាប់ឈ្មោះជួប សំណាង លើកទឡ្ហីករណ៍ថា: ឈ្មោះរដ្ឋ ផុន បានមកទំនាក់ទំនងប្អូនខ្ញុំបាទ ដើម្បីលក់ឈើ ហើយបាននាំគ្នាទៅមើលឈើដែលខ្លួនរក្សាទុកនៅក្នុងព្រៃ ពេលត្រឡប់មកភ្នំពេញវិញ ក៏បានធ្វើកិច្ចសន្យាកក់ប្រាក់អោយឈ្មោះរដ្ឋ ផុន ចំនួន ១២៣០០០ដុល្លា ពេលបានទទួលប្រាក់ហើយ ឈ្មោះនេះបានគេចវេះបាត់ ឈើក៏ពុំឃើញដឹកយកមកឱ្យ ពេលដែលខ្ញុំទៅរកដល់ផ្ទះ ឈ្មោះនេះបានលក់ផ្ទះបាត់ ហើយរត់គេចខ្លួនៗ ចំពោះកិច្ចសន្យាប្រគល់ប្រាក់៥០០០ ដុល្លាជាងនោះ ខ្ញុំបាទពុំទទួលស្គាល់ទេ ព្រោះពុំបានទទួលប្រាក់នោះសោះ ឯឈើដែលត្រូវទូទាត់ជាមួយប្រាក់ជាង៥០០០ ដុល្លានោះ ក៏ពុំបានទទួលដែរ ។

- បានស្ដាប់ជនជាប់ចោទឈ្មោះរដ្ឋ ផុន លើកទឡ្ហីករណ៍ថា: នៅខែ០២ ឆ្នាំ ១៩៩៧ ខ្ញុំបាទទំនាក់ទំនងរកស៊ីជាមួយឈ្មោះជួប ចាន់ ក្នុងការលក់ឈើ ហើយឈ្មោះជួបចាន់ បានទៅពិនិត្យដល់កន្លែងតម្កល់ឈើទុក ពេលពិនិត្យឃើញឈើហើយឈ្មោះជួប ចាន់ បានហៅខ្ញុំបាទ មកភ្នំពេញ ដើម្បីធ្វើកិច្ចសន្យាទិញលក់ ដោយបានកក់ប្រាក់អោយមួយចំនួន ។ ក្រោយមកឈើត្រូវរដ្ឋ . ចាប់អស់ ហេតុនេះខ្ញុំបាទពុំបានប្រគល់ឈើអោយឈ្មោះជួប ចាន់ តាមកិច្ចសន្យាទេ ។

- បានស្ដាប់លោកខៀវ សុផល មេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណី បានលើកទឡ្ហីករណ៍ថា: នៅថ្ងៃទី២៤ - ០២ - ៩៧ កូនក្ដីខ្ញុំក្រោយពីបានចុះទៅមើលឃើញឈើហើយ

...../....

ក៏ចុះកិច្ចសន្យាវិញជាមួយឈ្មោះរដ្ឋ ផុន ហើយបានកក់ប្រាក់ ចំនួន ១២៣០០ ដុល្លារអាមេរិក អោយទៅឈ្មោះរដ្ឋ ផុន ហើយរដ្ឋ ផុន សន្យាដឹកឈើមកអោយតាមក្រោយ ។ លុះរំលងបានពីរបីខែក្រោយមកឈ្មោះរដ្ឋ ផុន ពុំឃើញដឹកឈើយកមកអោយកូនក្តីខ្ញុំក៏តាមទៅមើលដល់កន្លែងតម្កល់ឈើទុក ទើបដឹងថា ឈើដែលរដ្ឋ ផុន នាំទៅមើលលើកមុននោះ ពុំមែនជាឈើរបស់រដ្ឋ ផុន ទេ ឯចំណែកឈ្មោះរដ្ឋ ផុន បានគេចខ្លួនបាត់ ។ នេះជាការឆបោកទាំងស្រុង ។ អាស្រ័យហេតុនេះ សូមតុលាការបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ។

- បានស្តាប់អ្នកស្រីយឹម ស៊ីម៉េន មេធាវីជនជាប់ចោទ បានលើកឡើងនាពេលសវនាការថា: ដើមបណ្តឹងរដ្ឋប្បវេណី បានទៅពិនិត្យឃើញឈើហើយៗ ក៏ត្រឡប់មកភ្នំពេញធ្វើកិច្ចសន្យាជាមួយឈ្មោះរដ្ឋ ផុន ដោយកក់ប្រាក់ ជាដំណាក់កាលៗ ម្តងបន្តិចៗ ពុំមែនកក់ប្រាក់ម្តងទាំងអស់នោះទេ នៅថ្ងៃទី៣១-០១-៩៩ ដើមបណ្តឹងរដ្ឋប្បវេណី បានចុះទៅវាស់ឈើ ហើយវាយតម្លៃជាទឹកប្រាក់ រួចទើបដើមបណ្តឹងរដ្ឋប្បវេណី យល់ព្រមចុះកិច្ចសន្យាទទួលប្រាក់ ។ ឯការដឹកឈើយកមកភ្នំពេញបាន ឬ មិនបាន វាជារឿងក្រោយរបស់គាត់ ។ កូនក្តីនាងខ្ញុំជាប់ឃុំឃាំងជាងមួយឆ្នាំហើយ សូមតុលាការពិចារណា ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថា: គ្មានយោបល់បន្ថែម .

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ .

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី របស់ជនជាប់ចោទ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិង របស់ជនជាប់ចោទ .

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៣ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ ១៩៩៩ របស់លោកដួប សំណាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់លោកដួប សំណាង ក្នុងសារណាចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ១៩៩៩ ថា អំពើរបស់លោករដ្ឋ ផុន ទាំងប៉ុន្មានជាអំពើឆបោកទាំងស្រុង នោះគឺជាការពុំត្រឹមត្រូវទេឡើយ ពីព្រោះថា លោកដួប សំណាង ក៏បានទទួលស្គាល់ថា កូនលោកឈ្មោះដួបចាន់ និងលោករដ្ឋ ផុន ពិតជាបានចុះកិច្ចសន្យាចុះថ្ងៃទី ២៤-០២-៩៧ ទិញលក់ឈើប្រាកដមែន ។

- យល់ឃើញថា ក្រោយពេលចុះកិច្ចសន្យា លោករដ្ឋ ផុន ពុំបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមការកំណត់ទេ ប៉ុន្តែពុំមានភស្តុតាងណាមួយបញ្ជាក់ថាឈ្មោះនេះ បានប្រើឧបាយកលទុច្ចរិត ដើម្បីឆបោកលោកដួប ចាន់ ឡើយ ហើយនៅថ្ងៃទី ៣១-៤-៩៩ ប្រពន្ធរបស់លោក បានសងប្រាក់ចំនួន ៥៨៣៣ ដុល្លារអាមេរិក អោយលោកដួប សំណាង លើប្រាក់កក់ចំនួន ១២.៣០០ ដុល្លារអាមេរិក

ហើយដែលជារឿងកិច្ចសន្យាលក់ទូលាធ ស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការរដ្ឋប្បវេណី ។

- យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី ពុំបានប្តឹងឧទ្ធរណ៍ពីសាលក្រមព្រហ្មទណ្ឌលេខ០៦ "ឃ" ចុះថ្ងៃទី០៣-១២-១៩៩៩ របស់តុលាការក្រុងភ្នំពេញទេ ហើយជនជាប់ចោទត្រូវឃុំខ្លួនអស់រយៈពេលជាងមួយឆ្នាំមកហើយ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៨៣ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ទាំងអង្គច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី
និង ជនជាប់ចោទ

១- ទទួលបណ្តឹងសាទុក្ខលេខ ៣៣ ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ ១៩៩៩ របស់លោក ជួប សំណាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាល់ខុសនឹងអង្គច្បាប់ ។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៨៣ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- បង្គាប់អោយដោះលែងជនជាប់ចោទឈ្មោះ រដ្ឋ ផុន ជាបន្ទាន់ពីពន្ធនាគារប្រសិនបើជននេះ ពុំមានជាប់ពីបទល្មើសផ្សេងទៀតទេ ។

៤- សាលដីកានេះប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី០៨ខែធ្នូ ឆ្នាំ ១៩៩៩ ។